ខ- ឆ្លើយរាល់សំណួរដែលត្រូវបានសួរដោយមន្ត្រីគយ ពាក់ព័ន្ធនឹងកិច្ចការទាំងឡាយដែលកើតឡើងក្រោមបញ្ញត្តិនៃច្បាប់នេះ ។

គ- បើកឱ្យដំណើរការនូវរាល់ឧបករណ៍ដើម្បីផ្តល់បង្ហាញនូវព័ត៌មានចាំបាច់នានាដល់មន្ត្រីគយតាមសំណើ ប្រសិនបើព័ត៌មានដូចមានចែងក្នុងកថាខណ្ឌខាងលើនៃមាត្រានេះត្រូវបានរក្សាទុកដោយមធ្យោបាយអេឡិចត្រូនិក ឬ ឧបករណ៍ផ្សេងទៀត ។

**មាត្រា ៥៣.-**

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អាចចេញប្រកាសកំណត់តម្រូវការដោយឡែកនានាពាក់ព័ន្ធនឹងឯកសារ បញ្ជីគណនេយ្យ កំណត់ត្រា និងបណ្តាព័ត៌មានផ្សេងទៀតក្រោមបញ្ញត្តិមាត្រា ៥១ នៃច្បាប់នេះ ។

## ជំពូកទី ៩

## ទំនិញគ្មានការទាមទារ

**មាត្រា ៥៤.-**

ទំនិញគ្មានការទាមទារគឺជា :

ក- ទំនិញរក្សាទុកក្នុងទីកន្លែងសន្និធិគយបណ្តោះអាសន្ន ឬ នៅក្នុងភណ្ឌាគារគយមានដែនកំណត់ ដែលហួសរយៈពេលកំណត់ក្រោមបញ្ញត្តិនៃច្បាប់នេះ ។

ខ- ទំនិញផ្ញើតាមប្រៃសណីយ៍ដែលគម្យជនបដិសេធមិនទទួលយក ឬ គម្យជនពុំត្រូវបានរកឃើញនិងមិនអាចបញ្ជូនទំនិញត្រឡប់ទៅអ្នកផ្ញើវិញបាន ។

គ- ទំនិញ និងមធ្យោបាយដឹកជញ្ជូនពុំជាប់អាយ័ត ដែលស្ថិតនៅក្នុងកន្លែងបញ្ចេញទំនិញពីគយ ហើយម្ចាស់បានបោះបង់ចោលជាលាយល័ក្ខណ៍អក្សរ ។

ប្រសិនបើម្ចាស់ទំនិញត្រូវបានស្គាល់ រដ្ឋបាលគយត្រូវផ្ញើដំណឹងជាបន្ទាន់ដល់ម្ចាស់ទំនិញគ្មានការទាមទារថា ទំនិញទាំងនោះនឹងត្រូវដាក់លក់ដោយដេញថ្លៃជាសាធារណៈស្របតាមបញ្ញត្តិមាត្រា ៥៥ នៃច្បាប់នេះ កាលណាពុំមានការទាមទារក្នុងរយៈពេលហុកសិប (៦០) ថ្ងៃ គិតពីថ្ងៃចេញសេចក្តីជូនដំណឹងនេះ ។

ក្នុងករណីពុំអាចរកម្ចាស់ឃើញ ប្រវេសន៍សាធារណៈត្រូវធ្វើតាមពេល និងរបៀប

ដែលនឹងកំណត់ដោយនាយកទីចាត់ការគយ និងរដ្ឋាករ ដើម្បីជាការជូនដំណឹងដល់ម្ចាស់ទំនិញ ។ ក្នុងរយៈពេលហុកសិប (៦០) ថ្ងៃ គិតចាប់ពីថ្ងៃចេញប្រវេសន៍នេះ ម្ចាស់ទំនិញត្រូវធ្វើការទាមទារទំនិញរបស់ខ្លួន ។ ប្រសិនបើហួសរយៈពេលនេះ ទំនិញនឹងត្រូវដាក់លក់ដោយដេញថ្លៃជាសាធារណៈស្របតាមបញ្ញត្តិនៃមាត្រា ៥៥ នៃច្បាប់នេះ ។

ក្នុងរយៈពេលដូចមានចែងក្នុងកថាខណ្ឌទី ២ និងកថាខណ្ឌទី ៣ នៃមាត្រានេះ ទំនិញគ្មានការទាមទារអាចអនុញ្ញាតឱ្យយកចេញពីគយបាន ក្រោយពីបានបង់ពន្ធ អាករ និងកម្រៃផ្សេងៗ និងទោសទណ្ឌនានា រួមទាំងល័ក្ខខ័ណ្ឌកម្រិតកំណត់ទាំងឡាយត្រូវបានបំពេញរួច ។

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អាចចេញប្រកាសកំណត់ករណីដែលទំនិញគ្មានការទាមទារអាចត្រូវបំផ្លាញចោល លក់ដោយដេញថ្លៃជាបន្ទាន់ ត្រូវបោះបង់ចោល ឬត្រូវប្រើប្រាស់សម្រាប់ប្រយោជន៍សាធារណៈផ្អែកតាមលក្ខណៈ ឬ តម្លៃទាបនៃទំនិញដោយធ្វើសេចក្តីជូនដំណឹងជាលាយល័ក្ខណ៍អក្សរជូនម្ចាស់ទំនិញ ឬ ចេញប្រវេសន៍សាធារណៈប្រសិនបើរកម្ចាស់ពុំឃើញ ។

**មាត្រា ៥៥.-**

ការលក់ទំនិញគ្មានការទាមទារ ត្រូវដាក់លក់ដោយដេញថ្លៃជាសាធារណៈ ។

នាយកទីចាត់ការគយ និងរដ្ឋាករ អាចកំណត់ថ្ងៃអប្បបរមាបានសម្រាប់ទំនិញដែលត្រូវដាក់លក់ដោយដេញថ្លៃ ។ ប្រសិនបើទំនិញមិនអាចត្រូវលក់ដាច់តាមថ្លៃនេះទេ នាយកទីចាត់ការគយ និងរដ្ឋាករ អាចកំណត់ថ្លៃអប្បបរមាថ្មីមួយ ឬ សុំការសម្រេចពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីបោះបង់ចោល ឬ ទុកប្រើប្រាស់សម្រាប់ផលប្រយោជន៍សាធារណៈ ។

ផលបានមកពីការលក់ត្រូវទូទាត់សងប្រាក់ពន្ធ និងអាករ ដែលមិនទាន់បានបង់កម្រៃ និងបន្ទុកផ្សេងៗ និងចំណាយរៀបចំការដាក់លក់ ដោយដេញថ្លៃ ។ ម្ចាស់ទំនិញអាចទាមទារយកនូវទឹកប្រាក់នៅសល់ក្រោយពីការទូទាត់នេះបាន ក្នុងរយៈពេលប្រាំមួយ (៦) ខែ តាមសេចក្តីជូនដំណឹងរបស់រដ្ឋបាលគយ ដែលត្រូវធ្វើឡើងក្នុងរង្វង់រយៈពេលប្រាំពីរ (៧)ថ្ងៃ បន្ទាប់ពីការលក់ដោយដេញថ្លៃ ។ ហួសរយៈពេលកំណត់នេះ ប្រសិនជាមិនមាន

ROYAUME DU CAMBODGE · LE MINISTRE DU PALAIS ROYAL



36/45

ការទាមទារយកទឹកប្រាក់នេះទេ នឹងក្លាយជាទ្រព្យសម្បត្តិរបស់រដ្ឋ ។

## ជំពូកទី ១០
## សិទ្ធិអំណាច និង ភារកិច្ច

**មាត្រា ៥៦.-**

មន្ត្រីគយមានសិទ្ធិអំណាចដូចមានចែងក្នុងច្បាប់នេះនៅក្នុងវង់អំណាចគយ ។ ក្នុងករណីដែលទំនិញត្រូវបានកំណត់ក្រោមបញ្ញត្តិនៃកថាខណ្ឌទី ២ ក្នុងមាត្រា ៨ នៃច្បាប់នេះ សិទ្ធិអំណាចរបស់មន្ត្រីគយត្រូវគ្របដណ្តប់នៅទូទាំងដែនគយ ។

ចំពោះទំនិញនាំចេញ ឬ នាំចូល មន្ត្រីគយមានសិទ្ធិអំណាចដូចតទៅ :

ក-ពិនិត្យទំនិញ ហើយបើក ឬ បញ្ជាឱ្យបើកកញ្ចប់ណាមួយ ឬ កុងតឺន័រទំនិញនិងអាចដកយកទំនិញបាន តាមចំនួនសមស្របសម្រាប់ការពិនិត្យ ។

ខ- ឃាត់ បញ្ឈប់ ឡើង ចូល និងត្រួតពិនិត្យឆែកឆេរ មធ្យោបាយដឹកជញ្ជូនទំនិញណាមួយ និងបញ្ជាឱ្យនាំមធ្យោបាយដឹកជញ្ជូនទំនិញនោះទៅការិយាល័យគយ ឬ ទីកន្លែងសមរម្យផ្សេងទៀតដើម្បីធ្វើការត្រួតពិនិត្យឆែកឆេរ ។

គ-ឆែកឆេរលំនៅស្ថានឯកជន ឬ ទីកន្លែងធុរកិច្ច ដើម្បីប្រមូលភ័ស្តុតាង ឬឃាត់ទុកទំនិញជាបណ្តោះអាសន្ន តាមបទប្បញ្ញត្តិ និងច្បាប់នានានៃព្រះរាជាណាចក្រកម្ពុជាក្នុងករណីមានការសង្ស័យដែលមានមូលដ្ឋានគួរឱ្យទុកចិត្តបានថាមានការប្រព្រឹត្តបទល្មើស ។

ឃ- ត្រួតពិនិត្យអត្តសញ្ញាណជនណាមួយដែលចូល ចេញដែនគយ ឃាត់ បញ្ឈប់ សួរ និងឆែកឆេរជននោះ ប្រសិនបើមន្ត្រីគយសង្ស័យថា ជននោះមានលាក់ទំនិញ ឬ របស់អ្វីផ្សេងទៀតនៅជុំវិញខ្លួននិងនៅក្នុងខ្លួនរបស់គេ ដែលអាចជាភ័ស្តុតាងនៃការរំលោភច្បាប់នេះ ឬ ច្បាប់ផ្សេងទៀតនៃព្រះរាជាណាចក្រកម្ពុជា ។

ចំណាយលើការត្រួតពិនិត្យដូចមានចែងក្នុងវាក្យខណ្ឌ ក និងវាក្យខណ្ឌ ខ កថាខណ្ឌទី ២ នៃមាត្រានេះ ជាបន្ទុករបស់ម្ចាស់ ឬ អ្នកទទួលកាន់កាប់ទំនិញ ឬ មធ្យោបាយដឹកជញ្ជូននោះ ។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *



35/45